# តើពេលវេលាធ្វើការអោយនរណា ?

ពេលវេលានយោបាយជាសម្ព័ន្ធមិត្តនឹងអំណាច បើសិនជាគ្មានប្រព័ន្ធ តាមដានត្រួតពិនិត្យវា អោយបានទៀងទាត់ ហៅថាអាណត្តិ និង គោលដៅច្បាស់លាស់ ហៅថា កម្មវិធីនយោបាយ។ នៅក្នុងបរិបទខ្មែរសព្វថ្ងៃ ពេលវេលា វាកំពុងបន្តធ្វើការឲរបបភ្នំពេញ បើសិនជាពួកអ្នកប្រជាធិបតេយ្យនិយម និង គណបក្សប្រឆាំង មានអត្ថសញ្ញាតែមួយគត់ ជាអាវុធសំរាប់ផ្លាស់ប្តូររបបដឹកនាំ គឺ កត្តាអន្តរជាតិ ដូចជា រង់ចាំ សហគមអឺរ៉ុបបញ្ឈប់ នូវការអនុគ្រោះពន្ធ (EBA) និង ច្បាប់សហរដ្ឋអាមេរិកស្តីពីបច្ចាប័នទៅលើពួកអ្នកដឹកនាំខ្មែរមួយចំនួន និង គ្រួសារផ្ទាល់របស់ ហ៊ុន សែន។ ទោះបីច្បាប់ទាំងនោះនឹងអាចមានកើតឡើង តែប្រជាពលរដ្ឋខ្មែរ មិនកម្រើក ដើបប្រឆាំងជាម្ចាស់ការនឹងរបបដឹកនាំផ្តាច់ការ កត្តានេះ វាគ្មានអនុភាពជាក់ស្តែង ទៅលើរបបភ្នំពេញនោះឡើយ។ ការទុកពេលវេលាឲរបបដឹកនាំ រស់នៅក្នុងផាសុកភាព នៃអំណាច គឺជាថ្នាំជីវជាតិសំរាប់ចិញ្ចឹមរបបផ្តាច់ការនោះឯង។ មួយជំហានម្តងៗ វាមិនឆ្លើយតបទៅនឹងបរិបទខ្មែរទៀតទេ ព្រោះពេលវេលានេះ វាជាពេលរបស់របបផ្តាច់ការ ប្រើគ្រប់មធ្យោបាយ ក្រៅផ្លូវច្បាប់ និង បង្កើតច្បាប់សំរាប់កម្រាមសឹកសត្រូវរបស់គេ ហើយ ដែលគេទុកជា សត្រូវទី១របស់គេ គឺ « សេរីភាព នៃប្រជាពលរដ្ឋ »។ អ្វីដែលជាគុណប្រយោជន៍មួយស្របក់ពេល ដែលរបបផ្តាច់ការគេផ្តល់ឲ វាជាតម្លៃ នៃការបាត់បង់ នូវសេរីភាពនេះឯង។

ឧប សៅ សង្ហា គំនិត ១៤ សីហា ២០១៨